# ស្ថានទូតអូស្ត្រាលី

# ភ្នំពេញ

# សេចក្តីប្រកាសព័ត៌មាន

## ចំនួនប្រជាពលរដ្ឋកម្ពុជាកាន់តែច្រើន
## បង្កើនការយល់ដឹងរបស់គេអំពីពិភពលោកតាមរយៈការអាន

លោកជំទាវ **ម៉ាហ្គារេត អាដាមសុន** **(Margaret Adamson)** ឯកអគ្គរាជទូតអូស្ត្រាលី និង ឯកឧត្តម **ថៃ នរៈសត្យា** រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានអញ្ជើញចូលរួមក្នុងពិធីបើកសម្ពោធវេទិកាសាធារណៈ ស្តីពីការអាននិងសរសេរនៅកម្ពុជា នៅបណ្ណាល័យជាតិនៅថ្ងៃនេះ ។ វេទិកានេះបានបានចូលរួមដោយអ្នកជំនាញចំនួនបួនរូប ដើម្បីពិភាក្សាជុំវិញបញ្ហាជំរុញអោយប្រជាពលរដ្ឋកម្ពុជាបង្កើនការយល់ដឹងរបស់ពួកគេអំពីពិភពលោក តាមរយៈការអាន និងការកោតសរសើរដល់ស្នាដៃសរសេរដែលមានគុណភាព ។

ដើម្បីជាការបន្តកិច្ចគាំទ្ររបស់ប្រទេសអូស្ត្រាលីដល់ស្ថាប័នវប្បធម៌ជាតិកម្ពុជា លោកជំទាវ អាដាមសុន ក៏បានប្រគល់ជូនបណ្ណាល័យជាតិកម្ពុជាផងដែរនូវកំរងសៀវភៅ ស្តីអំពី ទស្សនៈនាពេលបច្ចុប្បន្នរបស់ប្រទេសអូស្ត្រាលី រួមមាន ប្រព័ន្ធជីវៈចំរុះរបស់អូស្ត្រាលី ការប្រែប្រួលអាកាសធាតុ ប្រព័ន្ធផ្សព្វផ្សាយ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈជនជាតិដើម និងនយោបាយ ។

លោកជំទាវ **អាដាមសុន** បានមានប្រសាសន៍ថា "ការអានជាមធ្យោបាយមួយដែលងាយស្រួល និងចំណាយសោហ៊ុយតិច សំរាប់ពង្រីកចំណេះដឹងរបស់យើង អំពីវប្បធម៌របស់យើង និងវប្បធម៌របស់អ្នកដ៏ទៃ ។ អំណោយជាសៀវភៅពីស្ថានទូតអូស្ត្រាលីនាថ្ងៃនេះ នឹងផ្តល់ដល់សិស្ស និស្សិត អ្នកស្រាវជ្រាវកម្ពុជា នូវការយល់ដឹងដោយផ្ទាល់អំពីសង្គម និងវប្បធម៌របស់អូស្ត្រាលី"។ លោកជំទាវបានបន្តថា "ខ្ញុំសង្ឃឹមថា តាម រយៈសៀវភៅ និងធនធានដែលមាននៅបណ្ណាល័យជាតិ ប្រជាជនកម្ពុជានឹងយល់ដឹងបន្ថែមទៀតអំពីភាពសំបូរបែប នៃកេរ្តិ៍មរតកវប្បធម៌កម្ពុជា ក៏ដូចជាវប្បធម៌របស់ជាតិសាសន៍ដទៃទៀត" ។

ឯកឧត្តម **ថៃ នរៈសត្យា** បានមានប្រសាសន៍ថា "ការអាន និង ការសរសេរគឺជាស្នូលក្នុងការសំរេចបាននូវការសិក្សាប្រកបដោយជោគជ័យ ជួយបង្កើននូវការជឿទុកចិត្តលើការបញ្ចេញមតិដោយខ្លួនឯងដែលនាំអោយមានការរីកចំរើនជានិរន្តរ៍ដល់ខ្លួនយើង ។ ពិធីនៅថ្ងៃនេះគឺជាយន្តការមួយសំរាប់សិស្សានុសិស្ស និងនិស្សិត អ្នកអាន និង អ្នកស្រាវជ្រាវទាំងឡាយដែលមកពីគ្រប់ទិសទីទាំងអស់អោយបានយល់ដឹងអំពីសារសំខាន់នៃការអាននិងការសរសេរ" ។

អំណោយរបស់អូស្ត្រាលី រួមមាន ឯកសារនិងស៊ីឌីថតចំលងមួយច្បាប់ជាភាសារខ្មែរដែលបានដាក់ដំកល់នៅបណ្ណាល័យជាតិអូស្ត្រាលី ។ បណ្ណាល័យជាតិអូស្ត្រាលី គឺជាបណ្ណាល័យមួយក្នុងចំណោមបណ្ណាល័យធំជាងគេនៅលើពិភពលោក ដែលបង្កើតអោយមានការប្រមូលផ្តុំនូវការស្រាវជ្រាវយ៉ាងសកម្មបំផុតលើឯកសារនានានៅអាស៊ី ។ ឯកសារមួយក្នុងចំណោមឯកសារដ៏កម្រ និង មានតំលៃបំផុតដែលបណ្ណាល័យនេះតំកល់ទុកនោះ គឺឯកសារបកប្រែភាសាខ្មែរនៃគម្ពីត្រៃបិតក ។

ការចូលរួមពីសំណាក់អ្នកជំនាញជាច្រើនក្នុងវេទកាសារធារណៈស្តីពីការអាននិងការសរសេរនេះ រួមមានៈ លោកស្រី ខ្លូត វីបុលឡា នាយកបណ្ណាល័យជាតិកម្ពុជា លោក ហេង ស្រ៊ាង តំណាងមកពីអង្គការផិនកម្ពុជា លោកស្រី ប៉ាល់ វណ្ណ រីរាក់ តំណាងមកពីសមាគមន៍អ្នកនិពន្ធខ្មែរ និង លោកស្រី អាលីសុន ហាស តំណាងអ្នកនិពន្ធអាស៊ីលីង ២០១០ ដែលមកពីសមាគមន៍បណ្ណាល័យនូហាច ។

វេទកាសារធារណៈនេះ ដាក់តាំងបង្ហាញផងដែរ នូវឯកសារដ៏កម្រដែលតំកល់ទុកដោយបណ្ណាល័យជាតិកម្ពុជា ក៏ដូចជាការដាក់តាំងបង្ហាញដោយអ្នកបោះពុម្ភ អ្នកលក់សៀវភៅ និង អង្គការមួយចំនួនទៀតដែលពាក់ព័ន្ធទៅនឹងការលើកស្ទួយការអាន និង ការសរសេរនៅកម្ពុជា ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ
លោកស្រី **ហ្វីយ៉ូណា ខូឆ្ធ** ស្ថានទូតអូស្ត្រាលី ភ្នំពេញ
ទូរស័ព្ទលេខៈ ០២៣ ២១៣ ៤៧០
ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០